ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.១៣៩.....សហវ.ប្រក

# ប្រកាស
# ស្ដីពី
# ការកំណត់មូលដ្ឋានគិតអាករពិសេសលើមុខទំនិញដែលផលិតក្នុងស្រុកក្រៅពីបារីនិងស្រា

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការកែតម្រូវនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសប្រាប់ការគ្រប់គ្រងឆ្នាំ២០០១
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥០ អនក្រ.បក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលអត្រាអាករពិសេសលើមុខទំនិញមួយចំនួន
- បានឃើញប្រកាសលេខ ១១៣៣ សហវ.ពដ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៣ ស្ដីពីការណែនាំអនុវត្តការប្រមូលអាករពិសេសលើទំនិញ និងសេវាមួយចំនួន
- បានឃើញប្រកាសលេខ ៥២១ សហវ.ប្រក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤ ស្ដីពីការអនុវត្តអនុក្រឹត្យលេខ១៥០ អនក្រ.បក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលអត្រាអាករពិសេសលើមុខទំនិញមួយចំនួន
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

Collection by VCAT Professional Consultant



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CABOMDIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.-**

មូលដ្ឋានគិតអាករពិសេសលើមុខទំនិញដែលផលិតក្នុងស្រុក ក្រៅពីបារីនិងស្រា ដូចជា÷ ស្រាបៀរ ភេសជ្ជៈគ្មានជាតិសុរា និងមុខទំនិញជាប់អាករពិសេសដទៃទៀត ត្រូវបានកំណត់តាមច្បាប់ជាធរមាន។ មូលដ្ឋានគិតអាករនេះគឺជាថ្លៃផ្គត់ផ្គង់កត់ត្រាក្នុងវិក្កយបត្រឱ្យទៅអតិថិជនដោយមិនរួមបញ្ចូល÷

- អាករលើតម្លៃបន្ថែម និងអាករពិសេសខ្លួនឯង សម្រាប់អ្នកជាប់ពន្ធក្នុងរបបស្វ័យប្រកាស (របបពិត)
- អាករលើផលរបរ និងអាករពិសេសខ្លួនឯង សម្រាប់អ្នកជាប់ពន្ធក្នុងរបបម៉ៅការ។

**ប្រការ ២.-**

ពាក្យ “**ភេសជ្ជៈគ្មានជាតិសុរា**” ដែលជាកម្មវត្ថុនៃទំនិញជាប់អាករពិសេសផលិតក្នុងស្រុកនិងនាំចូល សំដៅដល់ ទឹកដែលមាន÷

- ជាតិឧស្ម័ន ឬ
- ដាក់ស្ករ ឬ
- ដាក់សារជាតិផ្អែមផ្សេងទៀត ឬ
- ដាក់គ្រឿងក្រអូប ឬ
- ភេសជ្ជៈដទៃទៀតដែលគ្មានជាតិសុរា លើកលែងតែ ទឹកនិងទឹកមីណេរ៉ាល ទឹកដោះគោ និងទឹកដមផ្លែឈើ ឬទឹកដមបន្លែ។

ពាក្យ “**ទឹកដមផ្លែឈើ ឬ ទឹកដមបន្លែ**” សំដៅដល់ ផលិតផលដែលផលិតចេញពីផ្លែឈើឬបន្លែសុទ្ធសាធពីធម្មជាតិ ដែលមានលក្ខខណ្ឌទាំងពីរ ដូចខាងក្រោម÷

- គ្មានការកែច្នៃរក្សាគុណភាព និងវេចខ្ចប់ តាមរូបភាពសិប្បកម្ម ឬឧស្សាហកម្ម និង
- គ្មានសារធាតុបន្ថែមរសជាតិ ឬក្លិន ឬពណ៌។

**ប្រការ ៣.-**

ប្រកាសលេខ៣៤៤ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៧ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៥ នេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង / ស្ថាប័ន
- សាលារាជធានី / ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ